# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០០៧ MIH / ២០១៧

សភាពាណិជ្ជកម្ម រាជធានីភ្នំពេញ
ចូល
លេខ: 039
ថ្ងៃទី 23/1/17 ម៉ោង 8.00AM
បញ្ជូន ...

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការការពារភាពមិនលំអៀង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៧៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការតែងតាំងឯកឧត្តម ចាន់ បូរិទ្ធ ជាប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- សេចក្តីសម្រេចលេខ ១១១៣ ឧរថ.វសក.សសរ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈ កម្មការការពារភាពមិនលំអៀងសម្រាប់វិញ្ញាបនបត្រកម្មប្រព័ន្ធ
- យោងសៀវភៅក្បួនគុណភាពសម្រាប់ប្រព័ន្ធគ្រប់គ្រង (Management Systems Manual) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ នៃវិទ្យាស្ថានស្តង់ដារកម្ពុជា
- យោងលិខិតលេខ ៣១៦៣ ជផ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងលិខិតលេខ ៣៩០៥ អ.តពង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិតលេខ ៦៣៦ អបស/ឱអបស ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងសុខាភិបាល
- យោងលិខិតលេខ២៨៥/១៦ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ របស់សភាពាណិជ្ជកម្មកម្ពុជា
- យោងលិខិតលេខ ៣៨ សមឧក ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ របស់សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

# សម្រេច

**ប្រការ១ ៖** បង្កើត គណៈកម្មការការពារភាពមិនលំអៀង (Certification Impartiality Committee) ហៅកាត់ថា CIC ស្ថិតក្រោមវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ២ ៖** សមាសភាពគណៈកម្មការការពារភាពមិនលំអៀងរួមមាន៖

| | | |
|---|---|---|
| ១- ឯកឧត្តម ចាន់ បូរិន្ទ | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | ជាប្រធាន |
| ២- លោក ចាន់ សូផា | អនុប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ៣- លោក សេង ឆាង | ប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម | សមាជិក |
| ៤-លោកស្រីបណ្ឌិត កៅ សុជីវី | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ៥- លោក ឌឹម ថេង | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- លោក អាំង ហុកស្រ៊ុន | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ✓៧-លោក ឡូញ គឹមអៀន | តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ៨- លោក ហេង ហ៊ាង | តំណាងសមាគមឧស្សាហកម្មតូច និងមធ្យមភ្នំពេញ | សមាជិក |
| ៩-លោក សោម ណូ | អនុប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម ទទួលបន្ទុកការងារវិញ្ញាបនបត្រកម្មប្រព័ន្ធ | លេខាធិការ |
| ១០-លោក លី ទីន | អនុប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម ទទួលបន្ទុកការងារវិញ្ញាបនបត្រកម្មផលិតផល | លេខាធិការ |

**ប្រការ៣ ៖** គណៈកម្មការការពារភាពមិនលំអៀងនេះមានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- បង្កើតគោលនយោបាយសម្រាប់ការគ្រប់គ្រងលើរាល់សកម្មភាព នៃការចេញវិញ្ញាបនបត្រកម្ម ដើម្បីការពារភាពមិនលំអៀង និងកសាងនូវទំនុកចិត្តរបស់ភាគីពាក់ព័ន្ធនានាដើម្បី៖
  - ទប់ស្កាត់នូវរាល់និន្នាការទាំងឡាយរបស់នាយកដ្ឋានវិញ្ញាបនបត្រកម្មដែលអាចនឹងរងឥទ្ធិពល ដោយសារកត្តាពាណិជ្ជកម្ម ឬដោយសារកត្តាផ្សេងទៀត សំដៅទទួលបាននូវភាពមិនលំអៀង និងភាពម៉ឺងម៉ាត់ក្នុងការផ្តល់សេវាកម្មវិញ្ញាបនបត្រកម្ម
  - ធានានូវភាពជឿជាក់ក្នុងការចេញវិញ្ញាបនបត្រ ភាពបើកចំហរ និងការយល់ឃើញរបស់សាធារណជន
- ត្រួតពិនិត្យឡើងវិញនូវភាពមិនលំអៀងនៃការធ្វើសវនកម្មក្នុងការចេញវិញ្ញាបនបត្រ និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនានារបស់នាយកដ្ឋានវិញ្ញាបនបត្រកម្មយ៉ាងតិចម្តងក្នុងមួយឆ្នាំ
- ត្រូវពិនិត្យមើលនូវការអនុវត្តគោលនយោបាយអំពីប្រព័ន្ធនៃការចេញវិញ្ញាបនបត្រ របស់នាយកដ្ឋានវិញ្ញាបនបត្រកម្ម និងមានសិទ្ធិសាកសួរព័ត៌មាន និងពិនិត្យឯកសារសំខាន់ៗ ដើម្បីមានលទ្ធភាពពេញលេញក្នុងការបំពេញសកម្មភាពរបស់ខ្លួន។

**ប្រការ៤ ៖** គណៈកម្មការការពារភាពមិនលំអៀងត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់តាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។ នៅពេលប្រធានអវត្តមានគណៈកម្មការខាងលើនេះអាចធ្វើការប្រជុំបានក្រោមការដឹកនាំរបស់សមាជិកតំណាងណាម្នាក់ដែលបានទទួលការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៥ ៖** គណៈកម្មការការពារភាពមិនលំអៀង អាចបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់ សម្រាប់ជាជំនួយការលើបញ្ហាបច្ចេកទេស និងបញ្ហានានាដែលពាក់ព័ន្ធនឹងការចេញវិញ្ញាបនបត្រ។

**ប្រការ៦ ៖** គណៈកម្មការការពារភាពមិនលំអៀងសម្រាប់វិញ្ញាបនបត្រកម្មប្រព័ន្ធផលិតផល ត្រូវបង្កើតនីតិវិធីរបស់ខ្លួនសម្រាប់ដំណើរការនៃការប្រជុំ។

**ប្រការ៧ ៖** សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ នឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨ ៖** នាយកខុទ្ទកាល័យ ប្រធានវិទ្យាស្ថាន ប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល៖</u>**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសុខាភិបាល
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ
  "ដើម្បីជូនជ្រាប"

-ដូចប្រការ៨ " ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ